គ.ជ.អ.ប
NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិនៃប្រទេសជប៉ុន

# សៀវភៅណែនាំ

# ស្តីពី

# ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត


រៀបរៀងដោយ
ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប
ផង គម្រោងសម្រាប់កិច្ចអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តច្បាប់រៀបចំអង្គការ
នៅថ្នាក់រាជធានី ខេត្ត ( PILAC 2 )



ខែកុម្ភៈ ឆ្នាំ២០១៤

# មាតិកា


ផ្នែកទី១៖ គោលបំណង និងទម្រង់សៀវភៅណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត 1

ផ្នែកទី២៖ គោលការណ៍នៃការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត 2

ផ្នែកទី៣៖ ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត 4

**ជំហានទី១÷ ការរៀបចំនិងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត** *4*

**១.១ ការរៀបចំឯកសារ និងព័ត៌មាន** 5

**១.២ កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 11

**ជំហានទី២÷ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត** *12*

**២.១ កិច្ចប្រជុំវិភាគស្ថានភាពរាជធានី ខេត្ត និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត** 12

**២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត** 15

**២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** 15

**២.៤ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** 16

**២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 18

**២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 18

**២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 19

**២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 20

**ជំហានទី៣÷ការអនុម័តនិងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានីខេត្ត** *20*

**៣.១ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 21

**៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** 23

ផ្នែកទី៤៖ ទម្រង់សៀវភៅ និងសេចក្តីពន្យល់ពីខ្លឹមសារសម្រាប់រៀបចំសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត 25

***៤.១. ទម្រង់សៀវភៅផែនការអភិវឌ្ឍន៍រាជធានីខេត្ត*** *25*

***៤.២. សេចក្តីពន្យល់ពីខ្លឹមសារសៀវភៅផែនការអភិវឌ្ឍន៍រាជធានីខេត្ត*** *26*

## ផ្នែកទី១÷ គោលបំណង និងទម្រង់សៀវភៅណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

សៀវភៅណែនាំនេះរៀបចំឡើងក្នុងគោលបំណងជួយដល់អ្នកពាក់ព័ន្ធក្នុងការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត និងដើម្បីៈ

- ស្វែងយល់កាន់តែច្បាស់អំពីខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត និង
- កសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានីខេត្ត ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិនិងមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធផ្សេងៗនៅក្នុងរាជធានីខេត្ត។

សៀវភៅណែនាំនេះនឹងត្រូវប្រើប្រាស់ដោយក្រុមប្រឹក្សា គណៈអភិបាល ក្រុមការងារកសាងផែនការ មន្ទីរ ពាក់ព័ន្ធរាជធានី ខេត្ត ទីចាត់ការនានានៃសាលារាជធានី ខេត្ត សង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដែលទាក់ទងនឹងការអភិវឌ្ឍនៅក្នុងរាជធានី ខេត្ត។

ទម្រង់សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

- ផ្នែកទី១ៈ គោលបំណង និងទម្រង់សៀវភៅណែនាំ
- ផ្នែកទី២ៈ គោលការណ៍នៃការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ផ្នែកទី៣ៈ ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ផ្នែកទី៤ៈ ទម្រង់សៀវភៅ និងសេចក្តីពន្យល់ពីខ្លឹមសារសម្រាប់កសាងសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ឧបសម្ព័ន្ធ

## ផ្នែកទី២៖ គោលការណ៍នៃការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម៖

១. ការចែករំលែកព័ត៌មាន
២. តម្លាភាព
៣. សង្គតិភាព និងសុខដុមនីយកម្ម
៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ
៥. ការឆ្លើយតបនឹងតម្រូវការ
៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
៧. ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម
៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
៩. ការធានាសមធម៌

អ្នកពាក់ព័ន្ធចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត ត្រូវកំណត់រកវិធី ឬមធ្យោបាយ ដែលអាចសម្រេចបានគោលការណ៍ទាំងនេះ និងកំណត់ពីស្ថានភាពដែលរាំងស្ទះដល់ការសម្រេចបាននូវគោលការណ៍ទាំងនេះ។ ដើម្បីស្វែងយល់អំពីគោលការណ៍នីមួយៗ សូមពិចារណាលើសំណួរបំផុសមួយចំនួនដូចខាងក្រោម៖

### សំណួរបំផុសទាក់ទងនឹងគោលការណ៍សំខាន់ៗទាំងប្រាំបួន(០៩)

| គោលការណ៍ | សំណួរបំផុស |
|---|---|
| ការចែករំលែកព័ត៌មាន | ▪ តើអ្នកនឹងផ្សព្វផ្សាយ និងចែករំលែកព័ត៌មានព្រមទាំងឯកសារចាំបាច់នានាស្តីពីផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត ជាមួយអ្ន ពាក់ព័ន្ធសំខាន់ៗតាមវិធីណា? |
| តម្លាភាព | ▪ តើអ្នកនឹងធានាឱ្យដំណើរការកសាង និងអនុវត្តន៍ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត មានតម្លាភាពចំពោះប្រជាពលរដ្ឋនៅក្នុងរាជធានី ខេត្តតាមវិធីណា? |
| សង្គតិភាព និងសុខដុមនីយកម្ម | ▪ តើអ្នកនឹងរៀបចំខ្លឹមសារនៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធ ខេត្ត ឱ្យមានសង្គតិភាពរវាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រ ជាតិផ្សេងៗគ្នាតាមវិធីណា? |
| ការចូលរួមពិគ្រោះយោបល់ជាទូទៅ | ▪ តើអ្នកនឹងធានាឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធ ផ្សេងៗតាមវិធីណា? |
| ការឆ្លើយតបនឹងតម្រូវការ | ▪ តើអ្នកនឹងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងដូចម្តេច? |
| គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ | ▪ តើអ្នកនឹងធ្វើយ៉ាងដូចម្តេចដើម្បីឱ្យរាជធានី ខេត្ត មានគណនេយ្យភាពនៅក្នុងដំណើរការ និងសមិទ្ធផលនៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត? |

| | |
|---|---|
| ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម | ▪ តើអ្នកនឹងចាត់វិធានការដែលមានបញ្ចូលនៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្តយ៉ាងដូចម្តេចដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចដែលបានគ្រោងទុកនៅក្នុងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |
| ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន | ▪ តើអ្នកធានាឱ្យមានការប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយចីរភាពនៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត យ៉ាងដូចម្តេច? |
| ការធានាសមធម៌ | ▪ តើអ្នកចាត់វិធានការ ដើម្បីសម្រេចបាននូវសមធម៌នៃការអភិវឌ្ឍសម្រាប់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនយ៉ាងដូចម្តេច? |

## ផ្នែកទី៣៖ ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត

ផ្នែកនេះបរិយាយអំពីសេចក្តីសង្ខេបស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត ដែលរួមបញ្ចូលទាំងការងារផ្នែករដ្ឋបាល។[1]

ការកសាងផែនការអភិវឌ្ឍន៍ចែកចេញជា៣ជំហានដូចខាងក្រោម៖

| |
|---|
| ជំហានទី១ ៖ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |
| ជំហានទី២ ៖ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |
| ជំហានទី៣ ៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |

**ជំហានទី១៖ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

**គោលបំណង**

- ដើម្បីរៀបចំ៖
  - ការណែនាំអំពីការបំពេញតារាងចាំបាច់នានាដោយក្រុង ស្រុក ខណ្ឌ បណ្តាមន្ទីររាជធានី ខេត្ត អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
  - ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និង
  - ទិន្នន័យព្រមទាំងឯកសារនានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។
- ដើម្បីផ្សព្វផ្សាយអំពី៖
  - ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
  - ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និង
  - ទិន្នន័យ ព្រមឯកសារនានាដែលត្រូវប្រើក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**លទ្ធផលរំពឹងទុក**

- តារាងវិភាគស្ថានភាពរៀបចំដោយអ្នកពាក់ព័ន្ធនីមួយៗ
- តារាងបូកសរុបការវិភាគស្ថានភាព
- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ឯកសារពាក់ព័ន្ធផ្សេងៗដូចជាឯកសារស្តីពីវឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាថ្នាក់ក្រោមជាតិ តារាងពិន្ទុវិស័យតាមបណ្តារាជធានី ខេត្ត ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្តចុងក្រោយគេនិងទិន្នន័យតាមវិស័យ
- ការយល់ដឹងកាន់តែប្រសើរឡើងពីដំណើរការ និងកិច្ចការកសាងផែនការអភិវឌ្ឍន៍ក្នុងចំណោមអ្នកពាក់ព័ន្ធស្តីពី៖

[1] សូមមើល "ផ្នែកទី៣៖ ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្តក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងឧបសម្ព័ន្ធ៦។

- តារាងបូកសរុបការវិភាគស្ថានភាព
- គោលការណ៍ណែនាំផ្នែកគោលនយោបាយ និង
- ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ដំណើរការ

ជំហានទី១ រួមមាន២សកម្មភាព ហើយសកម្មភាព១.១ បែងចែកជា៤សកម្មភាពតូចៗបន្ថែមទៀត។

១.១ ការរៀបចំឯកសារ និងព័ត៌មាន

១.១.១ ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

១.១.២ ការរៀបចំតារាងវិភាគស្ថានភាពរាជធានី ខេត្ត

១.១.៣ ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

១.១.៤ ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

១.២ កិច្ចប្រជុំដើម្បីផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**១.១ ការរៀបចំឯកសារ និងព័ត៌មាន**

**១.១.១ ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

ក) គោលបំណង

- ដើម្បីត្រៀមរៀបចំប្រតិទិនការងារសម្រាប់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលជាផែនការសកម្មភាពមួយ បង្ហាញពីសកម្មភាព ក្របខ័ណ្ឌពេលវេលា ទីកន្លែង អ្នកទទួលខុសត្រូវ និងធនធានដែលត្រូវការចាំបាច់នានា។

ខ) លទ្ធផលរំពឹងទុក

- ប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

គ) សមាសភាពចូលរួម

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ឃ) កិច្ចការដែលត្រូវធ្វើ

១. ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត (**សូមមើលឧបសម្ព័ន្ធ ៣៖ ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត**)។

២. គណៈអភិបាលរាជធានី ខេត្ត ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនអភិវឌ្ឍន៍រាជធានី ខេត្ត

៣. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

### ១.១.២ ការរៀបចំតារាងវិភាគស្ថានភាពរាជធានី ខេត្ត

ក) គោលបំណង

- ដើម្បីណែនាំស្ដីពីការបំពេញតារាងវិភាគស្ថានភាពដល់ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជននានានៅក្នុងរាជធានី ខេត្ត ។

ខ) លទ្ធផលរំពឹងទុក

- តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធនីមួយៗ
- តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

គ) សមាសភាពចូលរួម

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត និងតំណាងគណៈកម្មាធិការពាក់ព័ន្ធនានា
- តំណាងគណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងគណៈអភិបាលក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្ត
- តំណាងមន្ទីរ និងអង្គភាពនានាក្នុងរាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិលនានាក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជនសំខាន់ៗក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

ឃ) កិច្ចការដែលត្រូវធ្វើ

១. ក្រុមការងារកសាងផែនការរាជធានី ខេត្ត រៀបចំកិច្ចប្រជុំផ្ទៃក្នុងមុនកិច្ចប្រជុំណែនាំ ដើម្បីពិភាក្សា និងសម្រេច លើកិច្ចការចាំបាច់មួយចំនួនដូចខាងក្រោម៖

- ការរៀបចំឯកសារបទបង្ហាញ
- ការកំណត់សមាសភាពអ្នកចូលរួម និង
- លិខិតអញ្ជើញ ។

២. កិច្ចប្រជុំណែនាំត្រូវរៀបចំតាមរបៀបវារៈដូចខាងក្រោម៖

- បទបង្ហាញពីខ្លឹមសារសង្ខេបអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ទិន្នន័យ និងព័ត៌មានដែលត្រូវការសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- បទបង្ហាញ និងសេចក្ដីណែនាំពីការបំពេញតារាងវិភាគស្ថានភាពដោយប្រើប្រាស់ឧបករណ៍វិភាគដូចជាឧបករណ៍វិភាគបញ្ហាជាដើម **(សូមមើល ឧបសម្ព័ន្ធ ២.១៖ ការវិភាគបញ្ហា)**
- កំណត់កាលបរិច្ឆេទនៃការបញ្ជូនតារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធនីមួយៗត្រឡប់មកវិញ។

៣. អ្នកពាក់ព័ន្ធនីមួយៗរៀបចំ និងបញ្ជូនតារាងវិភាគស្ថានភាពមកឱ្យក្រុមការងារកសាងផែនការវិញ។

**ជំហាននេះរួមមានកិច្ចការដែលត្រូវធ្វើបួន (០៤)គឺ៖**

**កិច្ចការទី១៖ ការប្រមូលទិន្នន័យ និងការប្រៀបធៀបមុនការវិភាគ**

ជាបឋម អ្នកពាក់ព័ន្ធនីមួយៗ ប្រមូលទិន្នន័យមានស្រាប់ដែលទាក់ទងនឹងវិស័យ និងកិច្ចការអាទិភាពរបស់ខ្លួន។ បន្ទាប់មក អ្នកពាក់ព័ន្ធប្រៀបធៀបទិន្នន័យវិស័យតាមជំនាញរបស់ខ្លួនជាមួយនឹងទិន្នន័យថ្នាក់ជាតិ

ដើម្បីពិនិត្យថាតើ ទិន្នន័យថ្នាក់រាជធានី ខេត្ត អាចសម្រេចបានដូចទិន្នន័យថ្នាក់ជាតិ ឬទិន្នន័យមធ្យមថ្នាក់ជាតិដែរទេ ។ មិន ដូចពីមន្ទីរនានា ក្រុង ស្រុក ខណ្ឌ គួរគ្របដណ្តប់គ្រប់វិស័យ។ ទោះបីការរៀបចំ ផែនការអភិវឌ្ឍន៍ ក្រុង ស្រុក ខណ្ឌមានការពិបាក ក្រុង ស្រុក ខណ្ឌ ត្រូវព្យាយាមចាប់ផ្តើមដំណើរការ នេះ ឱ្យបានរួចរាល់ជាមុន។ បញ្ហាដែលពិបាក នឹងដោះស្រាយត្រឹមកម្រិត ក្រុង ស្រុក ខណ្ឌ អាចនឹង សមស្របត្រឹមកម្រិតផែនការអភិវឌ្ឍន៍ រាជធានី ខេត្ត។

**កិច្ចការទី២៖ ការជ្រើសរើសបញ្ហាដើម្បីវិភាគ**

ដោយគិតពីធនធានហិរញ្ញវត្ថុ និងធនធានមនុស្សនៅមានកម្រិត អ្នកពាក់ព័ន្ធ នីមួយៗជ្រើសរើសតែវិស័យអាទិភាព និងបញ្ហាមួយចំនួន ដែលជាអាទិភាពខ្ពស់ជាងគេក្នុងអាណត្តិ និងកិច្ចការរបស់ខ្លួន។ អ្នកពាក់ព័ន្ធអាចផ្តោតលើផ្នែកដែលពាក់ព័ន្ធនឹងកិច្ចការ ទំនួលខុសត្រូវ ការព្រួយបារម្ភ បញ្ហា និងតម្រូវការរបស់ខ្លួន ទោះបីជាតារាងរួមមា នផ្នែកខុសៗគ្នាដូចជាសេដ្ឋកិច្ច និងសង្គមកិច្ច ក៏ដោយ។ ឧទាហរណ៍៖មន្ទីរអប់រំ ខេត្ត ត្រូវបំពេញពីវិស័យអប់រំក្នុងតារាងផ្នែកសង្គមកិច្ច ។

**កិច្ចការទី៣៖ ការវិភាគបញ្ហា**

ការវិភាគបញ្ហាត្រូវធ្វើឡើងដោយយោងលើវិធីសាស្ត្រដែលបានពន្យល់ក្នុង "ឧបសម្ព័ន្ធ២.១ ការវិភាគបញ្ហា"។ ការវិភាគបញ្ហាគួរតែធ្វើឡើងសម្រាប់បញ្ហា និងវិស័យអាទិភាពនីមួយៗ ។

**កិច្ចការទី៤៖ ការស្រង់លទ្ធផលនៃការវិភាគបញ្ហានៅក្នុងតារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធនីមួយៗ**

អ្នកពាក់ព័ន្ធបំពេញតារាងការវិភាគស្ថានភាពដោយយោងលើវិធានដូចខាងក្រោម៖

| **ការវិភាគបញ្ហា** | **តារាងវិភាគស្ថានភាព** |
|---|---|
| បញ្ហាស្នូល | បញ្ហា |
| មូលហេតុផ្ទាល់/មូលហេតុរង | មូលហេតុ |
| បញ្ហាយេនឌ័រដែលមើលរំលង | តម្រូវការយេនឌ័រ |

*សម្គាល់៖ មូលហេតុផ្ទាល់ និងមូលហេតុរងនៃការវិភាគបញ្ហា គួរដាក់លេខសម្គាល់ដើម្បីបង្ហាញពីភាពខុសគ្នា ហើយស្រង់ចូលក្នុងកូឡោន"មូលហេតុ" នៃតារាងវិភាគស្ថានភាព។*

៤. ក្រុមការងារកសាងផែនការរៀបចំតារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ។

ក្រុមការងារកសាងផែនការចងក្រងតារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធដែលផ្តល់ដោយអ្នកពាក់ព័ន្ធ ចូលក្នុងតារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ (**សូមមើលឧបសម្ព័ន្ធ ៥.២**)។ បញ្ហាក្នុងតារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធត្រូវបានយកទៅបូកសរុបដោយពុំចាំបាច់ឆ្លងកាត់ការពិនិត្យ និងធ្វើការចាត់អាទិភាពនោះទេ។

### ១.១.៣ ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

**ក) គោលបំណង**

- ដើម្បីរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដែលជាឯកសារមូលដ្ឋានគ្រឹះសម្រាប់ណែនាំ និងតម្រង់ទិសដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត។

ខ) លទ្ធផលរំពឹងទុក

- សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

គ) សមាសភាពចូលរួម

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ឃ) កិច្ចការដែលត្រូវធ្វើ

១. អាទិភាពសម្រាប់គោលការណ៍ណែនាំផ្នែកគោលនយោបាយត្រូវកំណត់ ដោយផ្អែកលើតារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ ផែនការអភិវឌ្ឍន៍តាមវិស័យ វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជានៅថ្នាក់ក្រោមជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិចុងក្រោយគេ ស្ថានភាពបច្ចុប្បន្ន របស់រាជធានី ខេត្ត ទំហំនៃតម្រូវការ និងភាពងាយរងគ្រោះ។

*សម្គាល់៖ អាទិភាពដែលបានកំណត់ក្នុងគោលការណ៍ណែនាំផ្នែកគោលនយោបាយ មិនចាំបាច់លម្អិតពេកទេ ហើយត្រូវតែជាទិសដៅអភិវឌ្ឍន៍សាមញ្ញមួយ ពីព្រោះអ្នកពាក់ព័ន្ធនឹងពិភាក្សាលម្អិតនៅក្នុងជំហានទី២។*

ការវិភាគបញ្ហា តម្រូវការ និងសក្តានុពលក្នុងមូលដ្ឋានត្រូវតែធ្វើឡើងឲ្យបានចាប់រហ័ស ដូចនេះការវិភាគបែបSWOT គួរតែយកមកប្រើក្នុងកិច្ចការនេះ(**សូមមើលក្នុងឧបសម្ព័ន្ធ២.២ ការវិភាគ SWOT**)។

២. ក្រុមការងារកសាងផែនការរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ។
ក្រុមការងារកសាងផែនការរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ ដោយផ្អែកលើលទ្ធផលនៃការជ្រើសរើសបឋមនូវវិស័យអាទិភាព យុទ្ធសាស្ត្រ និងបញ្ហា។

គោលការណ៍ណែនាំផ្នែកគោលនយោបាយត្រូវរៀបរាប់ពីវិស័យដែលបានចាត់អាទិភាព និងបញ្ហានានាដោយផ្អែកលើលក្ខណៈសំខាន់ៗទាំងផ្នែកខាងក្នុង និងខាងក្រៅផងដោយមិនចាំបាច់មានការពន្យល់លម្អិត។

ទម្រង់៖ សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚๛๛

រដ្ឋបាលរាជធានី ខេត្តកខគ
លេខ…………

**សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយសម្រាប់រៀបចំផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

**ក្រុមប្រឹក្សា{ឈ្មោះរាជធានីខេត្ត}**

– យោងតាមច្បាប់ពាក់ព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ

**សម្រេច**

**ប្រការ ១** {បរិយាយពីគោលដៅនៃគោលការណ៍ណែនាំផ្នែកគោលនយោបាយ}

សេចក្តីសម្រេចនេះមានបំណងណែនាំអំពីគោលការណ៍ណែនាំផ្នែកគោលនយោបាយសម្រាប់ស ង ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៃឈ្មោះរាជធានី ខេត្ត

**ប្រការ ២** {ការកំណត់វិស័យ និងបញ្ហាអាទិភាពជាបឋម}

{ឈ្មោះរាជធានី ខេត្ត} ត្រូវផ្តោតលើការកំណត់វិស័យ និងបញ្ហាអាទិភាព។

- បញ្ជីវិស័យ និងបញ្ហាអាទិភាព

កាលបរិច្ឆេទ

{ឈ្មោះរាជធានី ខេត្ត} ក្រុមប្រឹក្សា

{ឈ្មោះប្រធានក្រុមប្រឹក្សា }

៣. គណៈអភិបាល ពិនិត្យសេចក្តីព្រាងសេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ។

៤. ប្រសិនបើចាំបាច់ ក្រុមការងារកសាងផែនការ កែសម្រួលសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយទៅតាមមតិយោបល់របស់គណៈអភិបាល។

៥. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ អនុម័ត និងចេញសេចក្តីសម្រេចគោលការណ៍ណែនាំផ្នែកគោលនយោបាយ។

**១.១.៤ ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា**

**ក) គោលបំណង**

- ដើម្បីរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា

**ខ) លទ្ធផលរំពឹងទុក**

- ឯកសារពាក់ព័ន្ធនានា
- បញ្ជីឯកសារពាក់ព័ន្ធ

**គ) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការរាជធានី ខេត្ត ប្រមូលឯកសារពាក់ព័ន្ធនានាដូចជា៖

- វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅថ្នាក់ក្រោមជាតិចុងក្រោយ
- ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត
- សេចក្តីសង្ខេបព័ត៌មានអំពីស្ថានភាពរាជធានីខេត្តតាមផ្នែកនីមួយៗ **សូមមើលឧបសម្ព័ន្ធ៤៖ ព័ត៌មានសំខាន់ៗអំពីស្ថានភាពរាជធានី ខេត្ត)**
- ឯកសារពត៌មានពីដៃគូអភិវឌ្ឍន៍នានាដែលមានសកម្មភាពអភិវឌ្ឍន៍នៅក្នុងរាជធានី ខេត្ត
- បណ្តាផែនទីធំៗ (ទំហំ A0 ឬ A1) សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រជុំកសាងផែនការដូចជា ៖
  - ផែនទីភូមិសាស្ត្ររដ្ឋបាលបង្ហាញពីព្រំប្រទល់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តដែលចេញដោយក្រសួងមហាផ្ទៃ
  - ផែនទីបង្ហាញពីដង់ស៊ីតេប្រជាជនតាមឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ
  - ផែនទីបង្ហាញពីការប្រើប្រាស់ដីធ្លីជម្មតា (តំបន់ទីប្រជុំជន កសិកម្ម ព្រៃឈើ ។ល។)
  - ផែនទីបង្ហាញអំពីហេដ្ឋារចនាសម្ព័ន្ធសង្គមសំខាន់ៗ (សាលាអនុវិទ្យាល័យ មណ្ឌលសុខភាព ការិយាល័យរដ្ឋបាលសាធារណៈ និងទីផ្សារជាដើម។ល។)
- ឯកសារផែនការអភិវឌ្ឍន៍ពីមុនរបស់រាជធានី ខេត្ត (បើមាន)
- ផែនការអភិវឌ្ឍន៍តាមវិស័យ និង/ឬផែនការអភិវឌ្ឍន៍របស់រដ្ឋបាលពាក់ព័ន្ធនានា
- ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- តារាងម៉ាទ្រិសសកម្មភាពអាទិភាពរបស់រាជធានី ខេត្ត (យកតាមកាលបរិច្ឆេទចុងក្រោយគេ)
- តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

២. ក្រុមការងារកសាងផែនការរាជធានី ខេត្ត រៀបចំបញ្ជីឯកសារ (សូមមើលទម្រង់គំរូខាងក្រោម)។

**ទម្រង់គំរូបញ្ជីតម្រូវការឯកសារ**

| ល.រ | ឈ្មោះឯកសារ | ប្រភេទ | កាលបរិច្ឆេទ | ប្រភព | ទីកន្លែងតម្កល់ | ផ្សេងៗ |
|---|---|---|---|---|---|---|

| ល.រ | ឈ្មោះឯកសារ | ប្រភេទ | កាលបរិច្ឆេទ | ប្រភព | ទីកន្លែងតម្កល់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**១.២ កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

ក) គោលបំណង

- ដើម្បីផ្សព្វផ្សាយពីៈ
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
  - កិច្ចការ និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការកស ងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត និង
  - ឯកសារពាក់ព័ន្ធនានាដែលជាមូលដ្ឋានសម្រាប់ប្រើប្រាស់ក្នុងការកសាងផែនការអភិវឌ្ឍន៍។

ខ) លទ្ធផលរំពឹងទុក

- ការយល់ដឹងកាន់តែប្រសើរអំពីដំណើរការ និងកិច្ចការក្នុងការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត នៅក្នុងចំណោមអ្នកពាក់ព័ន្ធ ។

គ) សមាសភាពចូលរួម

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងក្រុមប្រឹក្សាគ្រប់ក្រុង ស្រុក ខណ្ឌ
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនិងគណៈកម្មាធិការផ្សេងទៀតរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- តំណាងអង្គការសង្គមស៊ីវិលដែលមាននៅក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជនដែលមាននៅក្នុងរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់។

ឃ) កិច្ចការដែលត្រូវធ្វើ

ក្រុមការងារកសាងផែនការរាជធានី ខេត្ត រៀបចំឯកសារសម្រាប់ធ្វើបទបង្ហាញ និងចែកជូនអ្នកពាក់ព័ន្ធឱ្យបានមុនកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មាន។ របៀបវារៈសំខាន់ៗក្នុងអង្គប្រជុំរួមមានៈ

- បទបង្ហាញអំពីៈ
  - ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត
  - គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
  - ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ
  - ទិន្នន័យព័ត៌មានស្តីពីស្ថានភាពរាជធានី ខេត្ត

- វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅថ្នាក់ក្រោមជាតិ
- ប្រតិទិនការងារសម្រាប់ដំណើរកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

• បញ្ហាផ្សេងៗ ។

**ជំហានទី២ ៖ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

**គោលបំណង**

• ដើម្បីរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**លទ្ធផលរំពឹងទុក**

• សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

*សម្គាល់៖ ចំពោះផែនការអភិវឌ្ឍន៍រាជធានី ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍របស់ខណ្ឌ និងផែនការអភិវឌ្ឍន៍របស់សង្កាត់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី។*

**ដំណើរការ**

ជំហានទី២ បែងចែកជា៨សកម្មភាពដូចខាងក្រោម ៖

២.១ កិច្ចប្រជុំវិភាគស្ថានភាពរាជធានី ខេត្ត និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

២.៤ ការរៀបចំក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ

២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**២.១ កិច្ចប្រជុំវិភាគស្ថានភាពរាជធានី ខេត្ត និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**

**ក) គោលបំណង**

• ដើម្បីពិភាក្សា និងឯកភាពគ្នាពីបញ្ហា មូលហេតុនៃបញ្ហា គោលបំណង គោលដៅ និងដំណោះស្រាយក្នុងវិស័យនានាក្នុងរាជធានី ខេត្ត។

**ខ) លទ្ធផលរំពឹងទុក**

• តារាងវិភាគស្ថានភាពរាជធានី ខេត្ត ដែលបានចាត់អាទិភាព
• សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

**គ) សមាសភាពចូលរួម**

• គណៈអភិបាលរាជធានី ខេត្ត
• ក្រុមការងារកសាងផែនការរាជធានី ខេត្ត

- តំណាងមន្ទីរវិស័យ និងអង្គភាពនានានៅក្នុងរាជធានីខេត្ត
- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទាំងអស់នៅក្នុងរាជធានី ខេត្ត
- តំណាងអង្គការសង្គមស៊ីវិលនៅក្នុងរាជធានី ខេត្ត
- តំណាងវិស័យឯកជននៅក្នុងរាជធានី ខេត្ត

ឃ) កិច្ចការដែលត្រូវធ្វើ

១. ក្រុមការងារកសាងផែនការរាជធានី ខេត្ត ចែកតារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធសម្រាប់ជាឯកសារយោងដើម្បីពិភាក្សា។

២. អ្នកចូលរួមត្រូវបែងចែកជាបួន(៤)ក្រុម (ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ និងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ) ដើម្បីពិភាក្សា និងឯកភាពលើគ្នាការចាត់អាទិភាពបញ្ហានានា **(សូមមើលឧបសម្ព័ន្ធ ២ .៤៖ វិធីសាស្ត្រដាក់ពិន្ទុសម្រាប់ចាត់អាទិភាព )** មូលហេតុ និងដំណោះស្រាយនៅក្នុងអាណត្តិរបស់ក្រុមប្រឹក្សា ដោយត្រូវយកចិត្តទុកដាក់ចំពោះតម្រូវការយេនឌ័រដែលមើលរំលង។ ក្រុមនីមួយៗអាចប្រើប្រាស់ឧបករណ៍វិភាគដូចជា ឧបករណ៍វិភាគបញ្ហា ឧបករណ៍វិភាគដំណោះស្រាយ និងឧបករណ៍វិភាគផ្សេងៗទៀត ដើម្បីកំណត់ ឱ្យបានច្បាស់នូវបញ្ហា មូលហេតុ គោលបំណង គោលដៅ និងដំណោះស្រាយ។ **(សូមមើលឧបសម្ព័ន្ធ ២ .១៖ ការវិភាគបញ្ហា និង២.២៖ ការវិភាគដំណោះស្រាយ)**

ក្រុមនីមួយៗត្រូវពិភាក្សាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- **ផ្នែកសេដ្ឋកិច្ច៖** អាជីវកម្ម កសិកម្ម ឧស្សាហកម្ម គមនាគមន៍ សេវាកម្ម និងការវិនិយោគ។
- **ផ្នែកសង្គមកិច្ច៖** អប់រំ សុខាភិបាល និងភាពក្រីក្រ។
- **ផ្នែកការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ៖** ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។
- **ផ្នែកការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖** អភិបាលកិច្ច ការគ្រប់គ្រងដែនដី ការគ្រប់គ្រងស្ថិតិ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការងាររដ្ឋបាលទូទៅ និងការងារព្រំដែន។

៣. បន្ទាប់ពីការវិភាគ ក្រុមនីមួយៗត្រូវស្រង់លទ្ធផលនៃកិច្ចពិភាក្សាតាមផ្នែកនីមួយៗដោយត្រូវចម្លង៖

- *បញ្ហា មូលហេតុ*និង*តម្រូវការយេនឌ័រ*ចូលទៅក្នុងតារាងវិភាគស្ថានភាពដែលបានចាត់អាទិភាព **(សូមមើលឧបសម្ព័ន្ធ៥.៣៖ តារាងវិភាគស្ថានភាពរាជធានី ខេត្តដែលបានចាត់អាទិភាព)។**
  *សម្គាល់៖ ដំបូងក្រុមនីមួយៗពិនិត្យ និងពិភាក្សាអំពីបញ្ហា និងមូលហេតុនានានៅក្នុងផ្នែកនីមួយៗក្នុងតារាងបូកសរុបស្ថានភាពរបស់អ្នកពាក់ព័ន្ធពីទិដ្ឋភាពដូចខាងក្រោម៖*
  - ភាពត្រឹមត្រូវនៃការបញ្ជីបញ្ហា
  - ភាពច្បាស់លាស់នៃការរៀបរាប់

– ទំនាក់ទំនងប្រកបដោយភាពសមស្របរវាងបញ្ហានិងមូលហេតុ
បន្ទាប់មកទៀត ក្រុមនីមួយៗព្យាយាមកំណត់បញ្ហា និងមូលហេតុមិនឱ្យលើសពីប្រាំក្នុងផ្នែកនីមួយៗ។ ប៉ុន្តែវាមានការលំបាកក្នុងការកំណត់ចំនួនបញ្ហា និងមូលហេតុដោយគ្មានការប្រើប្រាស់វិធីសាស្ត្រចាត់អាទិភាព។
ដូចនេះវិធីសាស្ត្រដាក់ពិន្ទុអាចយកមកប្រើប្រាស់ជាជំនួយក្នុងការពិភាក្សា និងការឈានដល់ការស្រុះស្រួលគ្នា។

- *គោលបំណង គោលដៅ និងដំណោះស្រាយនៃការវិភាគដំណោះស្រាយ*ត្រូវបានលើកយកទៅរៀបរាប់ក្នុងសេចក្តីព្រាងនៃតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**សូមមើលឧបសម្ព័ន្ធ៥៖ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**
*សម្គាល់៖ គោលបំណង គោលដៅ និងដំណោះស្រាយត្រូវបានកំណត់ដោយប្រើប្រាស់ឧបករណ៍វិភាគបញ្ហា និងឧបករណ៍វិភាគរកដំណោះស្រាយ។បញ្ហា និងមូលហេតុជាប់ទាក់ទងគ្នាដោយទំនាក់ទំនងហេតុ និងផល ចំណែកឯទំនាក់ទំនងរវាងគោលបំណង គោលដៅ និងដំណោះស្រាយជាប់ទាក់ទងគ្នាដោយទំនាក់ទំនងមធ្យោបាយ និងលទ្ធផល ។*
*គោលបំណង គោលដៅ និងដំណោះស្រាយអាចកំណត់បានដោយបំប្លែងពីបញ្ហា និងមូលហេតុឲ្យទៅ ជាគោលបំណង គោលដៅ និងដំណោះស្រាយ គឺបង្កើតដើមឈើបញ្ហាឲ្យទៅជាដើមឈើដំណោះស្រាយ **(សូមមើលឧបសម្ព័ន្ធ ២.១ ការវិភាគបញ្ហា និងឧបសម្ព័ន្ធ ២.២ ការវិភាគដំណោះស្រាយ)**។*

| ការវិភាគស្ថានភាព | តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ |
|---|---|
| បញ្ហាស្នូល | គោលបំណង |
| មូលហេតុផ្ទាល់ | គោលដៅ |
| មូលហេតុរង | ដំណោះស្រាយ |

មូលហេតុផ្ទាល់ និងមូលហេតុរងនៃការវិភាគស្ថានភាពគួរដាក់លេខសម្គាល់ឲ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការបំប្លែងវាឲ្យជាគោលដៅនិងដំណោះស្រាយនៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍។

៤. ក្រុមនីមួយៗពិនិត្យភាពចាំបាច់ ដើម្បីបញ្ចូលបញ្ហាជាអាទិភាពដែលទទួលបានពីការវិភាគស្ថានភាពរបស់ក្រុង ស្រុក ខណ្ឌ ហើយដែលមិនបានលើកឡើងដោយក្រុមពិភាក្សា។
សម្គាល់៖ ក្រុមនីមួយៗពិនិត្យសេចក្តីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ថាតើបញ្ហា និងសេចក្តីណែនាំដែលត្រូវបានបង្ហាញនៅក្នុងគោលការណ៍ណែនាំផ្នែកគោលនយោបាយមានលក្ខណៈទូទៅក្នុងតារាងនេះហើយឬនៅ។
៥. ក្រុមនីមួយៗត្រូវធ្វើបទបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សារបស់ខ្លួននៅក្នុងកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួលសេចក្តីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត។

**ខ) ឯកសារដែលត្រូវប្រើសម្រាប់ការវិភាគស្ថានភាព**

- សេចក្តីសង្ខេបព័ត៌មានស្ថានភាពរាជធានី ខេត្ត
- បណ្តាផែនទីភូមិសាស្ត្រ រដ្ឋបាល សេដ្ឋកិច្ច និងធនធានធម្មជាតិ

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- តារាងពិន្ទុតាមវិស័យ( Sectoral Scorecard )ថ្នាក់រាជធានី ខេត្តថ្មីបំផុត
- ឯកសារស្តីពីស្ថានភាពរាជធានី ខេត្ត
- ឯកសារពាក់ព័ន្ធដទៃទៀត។

**២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**

**ក) គោលបំណង**

- ដើម្បីពិនិត្យ កែសម្រួល និងអនុម័តសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្តដែលបានអនុម័តរួច

**គ) សមាសភាពចូលរួម**

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- គណៈកម្មាធិការពាក់ព័ន្ធនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- អ្នកពាក់ព័ន្ធនានាដែលមានចំណេះដឹង និងបទពិសោធន៍ក្នុងការធ្វើផែនការ។

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការ ពិនិត្យ កែសម្រួល និងបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍។ ដើម្បីបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ ក្រុមការងារកសាងផែនការត្រូវអញ្ជើញតំណាងក្រុមប្រឹក្សារាជធានី ខេត្ត គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗ ដែលមានចំណេះដឹង និងបទពិសោធន៍ក្នុងការងារនេះ ដើម្បីចូលរួម និងផ្តល់មតិយោបល់ដូចជា ការផ្តល់យោបល់អំពីសូចនាករនៅក្នុងសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត (សូមមើល "ឧបសម្ព័ន្ធ៥.៤៖ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត") ។

២. គណៈអភិបាលរាជធានីខេត្តត្រូវដាក់សេចក្តីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ជូនក្រុមប្រឹក្សារាជធានីខេត្ត ពិនិត្យ និងអនុម័ត ដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់គណៈអភិបាលរាជធានីខេត្តរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាពិសេសគឺការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១។

៣. ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍។

**២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**

**ក) គោលបំណង**

- ប៉ាន់ស្មានថវិកាចំណាយនាពេលអនាគត ដែលជាមូលដ្ឋានសម្រាប់បំប្លែងផែនការអភិវឌ្ឍន៍ឱ្យទៅជាសកម្មភាពគម្រោងប្រចាំឆ្នាំ។

**ខ) លទ្ធផលរំពឹងទុក**

- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

គ) សមាសភាពចូលរួម

- ព័ត៌មានលម្អិតអំពីសមាសភាពចូលរួមនឹងត្រូវផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ឃ) កិច្ចការដែលត្រូវធ្វើ

- ព័ត៌មានលម្អិតអំពីកិច្ចការដែលត្រូវធ្វើនឹងណែនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.៤ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ក) គោលបំណង

- ដើម្បីរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ខ) លទ្ធផលរំពឹងទុក

- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

គ) សមាសភាពចូលរួម

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

ឃ) កិច្ចការដែលត្រូវធ្វើ

២.៤.១៖ ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

១. ក្រុមប្រឹក្សារាជធានីខេត្ត ត្រូវទទួលខុសត្រូវចំពោះការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ ដោយរាប់ទាំងផ្នែកនានានៃផែនការអភិវឌ្ឍន៍ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់៖
   - ក្រុមប្រឹក្សាប្រភេទរួមគ្នា
   - ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត
   - ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល និង
   - អ្នកពាក់ព័ន្ធនានា។

២. ការរៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្តត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖
   - ការរៀបចំផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
   - ការកំណត់សូចនាករសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
   - ការកំណត់អ្នកទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
   - ការកំណត់វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និង
   - ការកំណត់អ្នកចូលរួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

*សម្គាល់៖ ការកំណត់សូចនាករ*

សូចនាករ អាចរៀបចំឡើងដោយយោងលើលំដាប់ដូចខាងក្រោម ៖

១. កំណត់សូចនាករដោយមានបញ្ចូលព័ត៌មានចាំបាច់សម្រាប់គោលបំណង និងគោលដៅនីមួយៗ (សូមមើលឧទាហរណ៍ខាងក្រោម)។

២. ក្រុមការងារកសាងផែនការពិនិត្យ ថាតើមានទិន្នន័យណាខ្លះដែលសមស្របសម្រាប់សូចនាករ។

៣. ប្រសិនបើមានទិន្នន័យស្រាប់ សូមកត់ត្រាទិន្នន័យមូលដ្ឋាននៃឆ្នាំបច្ចុប្បន្ន (ឬឆ្នាំកន្លងមក) ក្នុងកូឡោន "បច្ចុប្បន្ន"។

៤. ប្រសិនបើមិនមានទិន្នន័យទេនោះ សូមពិចារណារកទិន្នន័យផ្សេងទៀតសម្រាប់សូចនាករ ។

៥. សូមពិចារណាពីសូចនាករគោលដៅក្នុងឆ្នាំមុនដែលរាជធានី ខេត្តចង់សម្រេចបាន។ សូចនាករគោលដៅនានាត្រូវមានភាពប្រាកដប្រជា ដោយពិចារណាលើ ក)ធនធានមនុស្ស និង ហិរញ្ញវត្ថុ និងខ)ក្របខ័ណ្ឌពេលវេលា (រយៈពេល ០៥ឆ្នាំ) ។

៦. នៅពេលមានការឯកភាពគ្នាលើសូចនាករគោលដៅហើយ សូមបំពេញកូឡោន"គោលដៅ" ដែលចង់បាន។

៧. កូឡោន "សេចក្តីសង្ខេប" ត្រូវបំពេញ ដោយប រិយាយអំពីសូចនាករជាក់លាក់ (សូមមើលឧទាហរណ៍ខាងក្រោម)។

៨. បន្ទាប់ពីសូនករត្រូវបានកំណត់៖ ក)អង្គភាពនានាដែលទទួលខុសត្រូវ ត្រូវផ្តល់ និងពិនិត្យលើទិន្នន័យសម្រាប់សូចនាករ និងខ) ប្រភពទិន្នន័យសម្រាប់សូចនាករត្រូវបានកំណត់ និងបំពេញចូល។

ឧទាហរណ៍៖ សូចនាករសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត

| កត្តាចំបាច់សម្រាប់សូចនាករ | ឧទាហរណ៍ |
|---|---|
| ១. វត្ថុ (អ្វី?) | ការផ្គត់ផ្គង់ទឹក |
| ២. អ្នកទទួលផល (ដើម្បីអ្នកណា?) | ប្រជាជន ២៥០០នាក់ (ស្ត្រី១៣០០នាក់) |
| ៣. បរិមាណ (ចំនួនប៉ុន្មាន ?) | ៣០ លីត្រសម្រាប់ម្នាក់ក្នុងមួយថ្ងៃ ដល់ប្រជាជន ៩០% |
| ៤. គុណភាព (ល្អកម្រិតណា?) | សម្រេចបានស្តង់ដានៃក្រុមហ៊ុនផ្គត់ផ្គង់ទឹក |
| ៥. កាលបរិច្ឆេទ (ត្រឹមពេលណា?) | ត្រឹមឆ្នាំ ២០១៩ |
| ៦. ទីកន្លែង (នៅកន្លែងណា?) | ស្រុក ក នៃខេត្ត ខ |
| → ទឹកដែលមានគុណភាពស្របតាមបទដ្ឋានរបស់ក្រុមហ៊ុនផ្គត់ផ្គង់ទឹក ត្រូវបានផ្គត់ផ្គង់ដល់៩០ភាគរយ នៃប្រជាជនចំនួន២៥០០នាក់ នៅក្នុងស្រុកកខគ ខេត្ត ចឆជ ដោយប្រជាជនម្នាក់ៗទទួលបានទឹកប្រើប្រាស់លើសពី ៣០ លីត្រក្នុងមួយថ្ងៃ នៅឆ្នាំ២០១៩។ | |

*សម្គាល់៖ ជាជម្រើស ការកំណត់សូចនាករ អ្នកទទួលខុសត្រូវសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃអាចនឹងត្រូវបានអនុវត្តក្នុងសកម្មភាព២.១ "កិច្ចប្រជុំស្តីពីការវិភាគស្ថានភាព និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត។ អ្នកពាក់ព័ន្ធចូលរួមនីមួយៗត្រូវស្នើឱ្យរៀបចំ និងផ្តល់នូវព័ត៌មានចាំបាច់ ដូចជាសូចនាករ អង្គភាពទទួលខុសត្រូវ និងប្រភពទិន្នន័យទៅកាន់ក្រុមការងារកសាងផែនការជាមុន ហើយអ្នកពាក់ព័ន្ធពិភាក្សា និងសម្រេចលើក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្តជាមួយរួមគ្នានឹងផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងសកម្មភាព២.១។*

**២.៤.២៖ ការរៀបចំនីតិវិធីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

១. នៅអំឡុងត្រីមាសទី៤ គណៈអភិបាលរាជធានី ខេត្ត ដោយមានទីចាត់ការផែនការនិងវិនិយោគជាសេនាធិការ ត្រូវប្រមូលទិន្នន័យដើម្បីបញ្ចូលក្នុងតារាងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ហើយត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ ដោយសហការជាមួយ នឹងតំណាងមន្ទីរ និងទីចាត់ការនានា។ **(សូមមើលឧបសម្ពន្ធ ២.៥៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ)**

ខ្លឹមសាររបាយការណ៍នេះរួមមាន៖

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម

២. គណៈអភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងកែសម្រួលសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ បន្ទាប់មកត្រូវដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត។

៣. ប្រសិនបើចាំបាច់ ក្រុមប្រឹក្សារាជធានីខេត្ត ពិនិត្យវឌ្ឍនភាពរបស់សូចនាករ និងឧបសគ្គ ហើយផ្តល់អនុសាសន៍សំខាន់ៗ ព្រមទាំងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ។

៤. ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើការណែនាំដល់គណៈអភិបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តរួច ជូនដល់អ្នកពាក់ព័ន្ធទាំងអស់។

៥. គណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍន៍ក្នុងរយៈពេលប្រាំមួយ(៦)ខែចុងក្រោយ នៃអាណត្តិរបស់ក្រុមប្រឹក្សា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានាសម្រាប់ការវាយតម្លៃបញ្ចប់អាណត្តិ។

## ២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ក) គោលបំណង**

- ដើម្បីរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**គ) សមាសភាពចូលរួម**

- ក្រុមការងារកសាងផែនការរាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការ រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដោយយោងតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។
**(សូមមើលផ្នែកទី៤ ទម្រង់សៀវភៅ សេចក្តីពន្យល់ពីខ្លឹមសារ និងវិធីសាស្ត្រសម្រាប់រៀបចំសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត)**

២. ក្នុងករណីចាំបាច់ ក្រុមការងារកសាងផែនការរាជធានី ខេត្ត អាចស្នើសុំការពន្យល់បន្ថែមពីសំណាក់ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍នេះ។

## ២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ក) គោលបំណង**

- ដើម្បីបង្ហាញពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តដល់អ្នកពាក់ព័ន្ធ
- ដើម្បីប្រមូលមតិយោបល់ និងអនុសាសន៍ក្នុងគោលបំណងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍

**ខ) លទ្ធផលរំពឹងទុក**

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលបានកែសម្រួល

**គ) សមាសភាពចូលរួម**

- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- តំណាងក្រុមប្រឹក្សាគ្រប់ក្រុង ស្រុក ខណ្ឌ
- តំណាងក្រុមប្រឹក្សាគ្រប់សង្កាត់ក្នុងរាជធានី ខេត្ត
- សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀត
- តំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធក្នុងរាជធានី ខេត្ត និង
- អ្នកពាក់ព័ន្ធដទៃទៀតតាមការចាំបាច់។

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. ក្រុមការងារកសាងផែនការ រៀបចំឯកសារសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ដូចខាងក្រោម ៖
- របៀបវារៈនៃកិច្ចប្រជុំ
- បទបង្ហាញស្តីពីខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍
- លិខិតអញ្ជើញដោយភ្ជាប់ជាមួយសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និង
- ឯកសារចាំបាច់ផ្សេងៗទៀត ដែលស្នើដោយគណៈអភិបាល។

២. គណៈអភិបាល/ក្រុមការងារកសាងផែនការ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដោយប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម៖
- បទបង្ហាញពីឯកសារនានាដែលរៀបចំដោយក្រុមការងារកសាងផែនការរាជធានីខេត្ត
- ក្នុងករណីចាំបាច់ អង្គប្រជុំអាចធ្វើការបែងចែកអ្នកចូលរួមជាក្រុម ដើម្បីពិភាក្សាលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ក្នុងនោះអាចមានប្រធានបទសំខាន់ៗដូចជាៈចក្ខុវិស័យអភិវឌ្ឍន៍ គោលបំណង គោលដៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ព្រមទាំងស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនានា។ មតិយោបល់ និងអនុសាន៍នានារបស់ក្រុមពិភាក្សាត្រូវប្រមូល និងកត់ត្រាទុក។

៣. ក្រុមការងារកសាងផែនការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់។

## ២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ក) គោលបំណង**

- ដើម្បីកែសម្រួលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដោយគណៈអភិបាលរាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលបានកែសម្រួល

គ) សមាសភាពចូលរួម

- គណៈអភិបាលរាជធានី ខេត្ត

ឃ) កិច្ចការដែលត្រូវធ្វើ

១. បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីក្រុមការងារកសាងផែនការ គណៈអភិបាលរាជធានីខេត្ត ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ មុននឹងដាក់ជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានីខេត្ត។ កិច្ចប្រជុំនេះត្រូវអនុវត្តទៅតាមរបៀបរបបការងាររបស់គណៈអភិបាលរាជធានី ខេត្ត ។

២. នៅពេលទទួលបានយោបល់ពីគណៈអភិបាលរាជធានីខេត្ត ក្រុមការងារកសាងផែនការត្រូវធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្តឱ្យបានត្រឹមត្រូវទៅតាមយោបល់របស់គណៈអភិបាលរាជធានី ខេត្ត។

**២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើ សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

ក) គោលបំណង

- ដើម្បីកែសម្រួលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដោយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ខ) លទ្ធផលរំពឹងទុក

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តដែលបានកែសម្រួល

គ) សមាសភាពចូលរួម

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ឃ) កិច្ចការដែលត្រូវធ្វើ

១. បន្ទាប់ពីការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍តាមយោបល់របស់គណៈអភិបាលរាជធានី ខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍នេះ។

២. នៅពេលទទួលបានយោបល់ពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលរាជធានីខេត្ត ត្រូវណែនាំក្រុមការងារកសាងផែនការឱ្យកែសម្រួលបញ្ចប់សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្តឡើងវិញឱ្យបានត្រឹមត្រូវទៅតាមយោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត រួចហើយ ត្រូវដាក់ជូនក្រុមប្រឹក្សារាជធានីខេត្ត ពិនិត្យ និងអនុម័ត។

**ជំហានទី៣៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

គោលបំណង

- ដើម្បីពិនិត្យ អនុម័ត និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត សម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា និងប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ។

លទ្ធផលរំពឹងទុក

- ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលបានអនុម័ត
- ខ្លឹមសារផែនការអភិវឌ្ឍន៍បានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ។

**ដំណើរការ**

ជំហានទី៣ រួមមាន២សកម្មភាព ហើយសកម្មភាព៣១ បែងចែកជា ៣សកម្មភាពតូចៗ និង សកម្មភាព៣២ បែងចែកជា ២សកម្មភាពតូចៗបន្ថែមទៀត។

| | |
|---|---|
| ៣.១ | ការអនុម័តផែនការអភិវឌ្ឍន៍ |
| ៣.១.១ | ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត |
| ៣.១.២ | កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត |
| ៣.១.៣ | ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត |
| ៣.២ | ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |
| ៣.២.១ | ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |
| ៣.២.២ | ការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត |

### ៣.១ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

#### ៣.១.១ ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

**ក) គោលបំណង**

- ដើម្បីត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- របៀបវារៈនៃកិច្ចប្រជុំ
- សេចក្តីថ្លែងហេតុ
- ឯកសារបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- លិខិតអញ្ជើញ

**គ) សមាសភាពចូលរួម**

- គណៈអភិបាលរាជធានី ខេត្ត
- ក្រុមការងារកសាងផែនការរាជធានី ខេត្ត
- ទីចាត់ការផែនការ និងវិនិយោគនៃសាលារាជធានី ខេត្ត
- នាយករដ្ឋបាលនៃសាលារាជធានី ខេត្ត
- អ្នកពាក់ព័ន្ធ និងអ្នកសង្កេតការណ៍នានា ចូលរួមតាមការអនុញ្ញាតពីប្រធានក្រុមប្រឹក្សារាជធានី ខេត្ត

**ឃ) កិច្ចការដែលត្រូវធ្វើ**

ក្រុមការងារកសាងផែនការដោយមានជំនួយពីទីចាត់ការផែនការនិងវិនិយោគ និងទីចាត់ការរដ្ឋបាលនៃសាលារាជធានី ខេត្ត ត្រូវរៀបចំកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- របៀបវារៈនៃកិច្ចប្រជុំ
- សេចក្តីថ្លែងហេតុ

- ឯកសារបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- លិខិតអញ្ជើញ ដោយភ្ជាប់ជាមួយសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត និងឯកសារពាក់ព័ន្ធផ្សេងទៀត *(សម្គាល់៖ឯកសារទាំងនេះត្រូវផ្ញើជូនដល់អ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិច(យ៉ាង)ថ្ងៃមុនកិច្ចប្រជុំ)*
- កិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលរាជធានី ខេត្ត។

**៣.១.២ កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត**

**ក) គោលបំណង**

- ដើម្បីពិនិត្យ កែសម្រួល និងអនុម័តលើសេចក្តីព្រាងបញ្ចប់ ស្តីពីផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ខ) លទ្ធផលរំពឹងទុក**

- សេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត

**គ) សមាសភាពចូលរួម**

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- អ្នកពាក់ព័ន្ធផ្សេងៗទៀត

**ឃ) កិច្ចការដែលត្រូវធ្វើ**

១. អភិបាលរាជធានី ខេត្តអានសេចក្តីថ្លែងហេតុ និងធ្វើបទបង្ហាញអំពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍

២. ក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍

៣. ផ្សេងៗ

*សម្គាល់៖ កិច្ចប្រជុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវដំណើរការតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។*

**៣.១.៣ ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត**

**ក) សមាសភាពចូលរួម**

- ក្រុមប្រឹក្សារាជធានី ខេត្ត
- គណៈអភិបាលរាជធានី ខេត្ត
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រសួងមហាផ្ទៃ
- ក្រសួងពាក់ព័ន្ធផ្សេងទៀត។

**ខ) កិច្ចការដែលត្រូវធ្វើ**

**១. ការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

គណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្ត នូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះដើម្បីពិនិត្យ និងផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប។

**២. ការត្រួតពិនិត្យអនុលោមភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

បន្ទាប់ពីទទួលបានសេចក្តីព្រាងផែនការអភិវឌ្ឍន៍ពីអភិបាលរាជធានីខេត្ត លេខាធិការដ្ឋានគ.ជ.អ.ត្រូវធ្វើការថតចម្លងសេចក្តីព្រាងនេះជូនក្រសួងមហាផ្ទៃក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនោះមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានាដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់និង សង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ក្រោយពេលពិនិត្យនិងពិគ្រោះយោបល់រួចរាល់ហើយលេខាធិការដ្ឋានគ.ជ.អ.ត្រូវធ្វើកំណត់បង្ហាញសុំយោបល់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃគិតពីថ្ងៃដែលទទួលបានពីអភិបាលរាជធានី ខេត្ត។ រយៈពេល ៣០ថ្ងៃនេះរួមមានពេលវេលាចំណាយសម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានីខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយក្រសួងមហាផ្ទៃលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានីខេត្ត និងក្រសួងមហាផ្ទៃអំពីខ្លឹមសារសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានីខេត្តក្រសួងមហាផ្ទៃត្រូវរាយការណ៍និងស្នើសុំមកគ.ជ.អ.ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីក្រសួងមហាផ្ទៃ ផ្ញើទៅអភិបាលរាជធានីខេត្តទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវចាត់ទុកថា ទទួលបាន ការត្រួតពិនិត្យអនុលោមភាពពីក្រសួងមហាផ្ទៃ។

ក្នុងករណីមានយោបល់កែសម្រួលលើសេចក្តីផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដោយក្រសួងមហាផ្ទៃ គណៈអភិបាលរាជធានី ខេត្ត ធ្វើការពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ទៅតាមយោបល់ដែលទទួលបាន ហើយដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តឡើងវិញ ដោយផ្តោតតែលើចំណុចដែលបានកែសម្រួលប៉ុណ្ណោះ។

៣. សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

បន្ទាប់ពីការអនុម័តរបស់ក្រុមប្រឹក្សា គណៈអភិបាលត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា។ ក្នុងករណីចាំបាច់ ក្រុមប្រឹក្សារាជធានី ខេត្ត អាចធ្វើការកែតម្រូវផែនការអភិវឌ្ឍន៍ក្នុងអំឡុងពេលនៃការអនុវត្តផែនការនេះ ផ្អែកតាមការស្នើសុំរបស់គណៈអភិបាលរាជធានី ខេត្ត។

**៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

**៣.២.១ ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

១. គណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ហើយត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត និងផ្ញើទៅក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

**៣.២.២ ការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

១. ក្រុមប្រឹក្សារាជធានី ខេត្តត្រូវណែនាំដល់គណៈអភិបាលរាជធានី ខេត្ត ដើម្បីផ្សព្វផ្សាយខ្លឹមសារផែនការអភិវឌ្ឍន៍រាជធានី ខេត្ត អោយបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដទៃ ។

២. ការផ្សព្វផ្សាយ អាចធ្វើឡើងតាមរយៈមធ្យោបាយផ្សេងៗមានដូចជា សារព័ត៌មាន កិច្ចប្រជុំផ្សព្វផ្សាយក្តារព័ត៌មាន ។ល។

# ផ្នែកទី៤÷ ទម្រង់សៀវភៅ
# និងសេចក្តីពន្យល់ពីខ្លឹមសារសម្រាប់រៀបចំសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ផ្នែកទី៤នេះ ពន្យល់ពីវិធីរៀបចំខ្លឹមសារនៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត រួមមានការពន្យល់លម្អិតពីជំហាននីមួយៗ។

## ៤.១. ទម្រង់សៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ទម្រង់សៀវភៅនៃផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ដែលត្រូវបានពន្យល់នៅក្នុងសេចក្តីណែនាំបច្ចេកទេសមានបង្ហាញដូចខាងក្រោម៖

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

អារម្ភកថា

សេចក្តីផ្តើម

ផែនទីរាជធានី ខេត្ត

**ជំពូកទី១÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច**

១.១. សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

១.២.១. ស្ថានភាពសេដ្ឋកិច្ច

១.២.២. ស្ថានភាពសង្គមកិច្ច

១.២.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

១.២.៤. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ជំពូកទី២÷ ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**

២.១. ចក្ខុវិស័យអភិវឌ្ឍន៍

២.២. គោលបំណងអភិវឌ្ឍន៍

២.៣. គោលដៅអភិវឌ្ឍន៍

២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍

២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

២.៤.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

២.៤.៣. យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

២.៤.៤. យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

២.៥. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

**ជំពូកទី៣÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

ឧបសម្ព័ន្ធ

## ៤.២. សេចក្តីពន្យល់ពីខ្លឹមសារសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ខ្លឹមសារនៃផ្នែកនីមួយៗ នឹងពន្យល់យ៉ាងលម្អិតរួមទាំងការពណ៌នាពីវិធីសាស្ត្រដែលត្រូវប្រើប្រាស់។

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

បន្ទាប់ពីទំព័រគម្របសៀវភៅគឺជាសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។ ខ្លឹមសារសំខាន់ៗដែលត្រូវបញ្ចូលក្នុងសេចក្តីសម្រេចមានដូចជា៖

ក) ការប្រកាសដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

ខ) ការណែនាំដល់គណៈអភិបាលរាជធានី ខេត្ត ក្នុងការផ្សព្វផ្សាយ ការអនុវត្ត និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

*<u>សម្គាល់</u>៖ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ។*

**អារម្ភកថា**

អារម្ភកថាត្រូវផ្តោតទៅលើសារៈសំខាន់នៃការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងសេចក្តីសង្ឃឹមដែលទទួលបានការគាំទ្រពីភាគីពាក់ព័ន្ធ។

**សេចក្តីផ្តើម**

សេចក្តីផ្តើមត្រូវពន្យល់ពីគោលបំណង និងសេចក្តីសង្ខេបការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្នុងមួយទំព័រ។

**ផែនទីរាជធានី ខេត្ត**

ផែនទីសំខាន់ៗដែលត្រូវបញ្ចូលរួមមានដូចជា៖

១) ផែនទីរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធ

២) ផែនទីការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ

៣) ផែនទីភាពក្រីក្រ

៤) ផែនទីផ្ទៃដី និងចម្ងាយ ។

ផែនទីទាំងនេះត្រូវយកចេញពីប្រភពល្អបំផុតដូចជា៖

- សៀវភៅទិន្នន័យរាជធានីខេត្តចុងក្រោយគេ
- មន្ទីរនិង/ឬ អង្គការពាក់ព័ន្ធ

## ជំពូកទី១ ៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

### ១.១. សេចក្ដីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

សេចក្ដីណែនាំបច្ចេកទេស បង្ហាញពីភាពបត់បែនក្នុងការបំពេញ "តារាងសេចក្ដីសង្ខេបព័ត៌មានស្ថានភាពរាជធានីខេត្ត" ។អ្នកទទួលខុសត្រូវ(ឧទាហរណ៍៖ ក្រុមការងារកសាងផែនការ)ត្រូវបំពេញតារាងដោយប្រើប្រាស់៖

១) ឯកសារព័ត៌មានស្ថានភាពឃុំសង្កាត់ ក្រុងស្រុកខណ្ឌ រាជធានី ខេត្ត (មន្ទីរផែនការ)

២) ទិន្នន័យផ្នែកអប់រំ (មន្ទីរអប់រំ)

៣) ទិន្នន័យផ្នែកសុខភាព (មន្ទីរសុខាភិបាល)

៤) ទិន្នន័យផ្នែកអភិវឌ្ឍន៍ជនបទ (មន្ទីរអភិវឌ្ឍន៍ជនបទ)

៥) ទិន្នន័យផ្នែកឧស្សាហកម្ម (មន្ទីរឧស្សាហកម្ម និងមន្ទីរពាណិជ្ជកម្ម)

៦) ទិន្នន័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

៧) សៀវភៅកម្រងទិន្នន័យស្ថិតិប្រចាំឆ្នាំ (ក្រសួងផែនការ)

៨) សៀវភៅទិន្នន័យរាជធានី ខេត្ត របស់គ.ជ.អ.បចុងក្រោយគេ

៩) គេហទំព័រគ.ជ.អ.ប

១០) ទិន្នន័យពាក់ព័ន្ធផ្សេងទៀត ។

**តារាងព័ត៌មានសំខាន់ៗក្នុងរាជធានី ខេត្ត**

| បរិយាយ | ឯកតា | ឆ្នាំ២០១៨ |
|---|---|---|
| ផ្ទៃដីរាជធានី ខេត្ត | គ.ម$^{២}$ | |
| ចំនួនក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ | |
| ចំនួនឃុំ សង្កាត់ | ឃុំ សង្កាត់ | |
| ចំនួនភូមិ | ភូមិ | |
| ចំនួនប្រជាជនសរុប | នាក់ | |
| ចំនួនស្ត្រីសរុប | នាក់ | |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | |
| ចំនួនគ្រួសារសរុប | គ្រួសារ | |
| អត្រាមេគ្រួសារជាស្ត្រី | % | |
| អត្រាគ្រួសារមានមុខរបរ.......ជាចម្បង | % | |
| អត្រាកុមារអាយុ៦-១៤ឆ្នាំ មិនបានចូលរៀន | % | |
| អត្រាអ្នកមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | |
| អត្រាស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | |
| ចំនួនស្ត្រីសម្រាលកូនសរុប | នាក់ | |
| អត្រាស្ត្រីសម្រាលកូនដោយពេទ្យឆ្មប | % | |
| មរណភាពមាតាក្នុង ១០ម៉ឺន កំណើតក្រោយពេលសម្រាលកូនពី ០-១ខែ | នាក់ | |
| អត្រាគ្រួសារប្រើប្រាស់ទឹកម៉ាស៊ីន | % | |
| អត្រាគ្រួសារប្រើប្រាស់អណ្ដូងទឹកស្អាត | % | |
| សមាមាត្រគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | % | |

រាជធានី ខេត្ត អាចបន្ថែមទិន្នន័យសេដ្ឋកិច្ចពីប្រភពខាងលើបាន ទោះបីជាតារាងព័ត៌មានសំខាន់ៗក្នុងរាជធានី ខេត្ត ដែលមាននៅក្នុងសេចក្តីណែនាំបច្ចេកទេសមិនមានបញ្ចូលទិន្នន័យសេដ្ឋកិច្ចទាំងនេះក៏ដោយ។ រាជធានី ខេត្តអាចពិចារណា និងជ្រើសរើសសកម្មភាពសេដ្ឋកិច្ចសំខាន់ៗ និងទិន្នន័យដែលបញ្ជាក់ពីស្ថានភាពនៃសកម្មភាពទាំងនោះ ។

**ឧទាហរណ៍អំពីទិន្នន័យទូទៅនៃសកម្មភាពសេដ្ឋកិច្ច**

| សកម្មភាពសេដ្ឋកិច្ច | ទិន្នន័យ |
|---|---|
| កសិកម្ម កសិឧស្សាកម្ម | ទិន្នផល និងផលិតផលស្រូវ ចំនួនរោងម៉ាស៊ីនកិនស្រូវ |
| ពាណិជ្ជកម្ម (លក់ដុំ និងរាយ) | ចំនួនអ្នកលក់ដុំ និងអ្នកលក់រាយដែលបានចុះបញ្ជី |
| ទេសចរណ៍ | ចំនួនសណ្ឋាគារ និងភោជនីយដ្ឋាន ចំនួនទេសចរជាតិ និងអន្តរជាតិ |
| ឧស្សាហកម្ម | ផលិតកម្មឧស្សាហកម្ម (ឧទាហរណ៍៖ រោងចក្រកាត់ដេរ) ចំនួនបុគ្គលិក ចំនួនក្រុមហ៊ុនដែលបានចុះបញ្ជី |

### ១.២. ស្ថានភាពបច្ចុប្បន្ន និង បញ្ហាប្រឈម

ការសរសេរពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ត្រូវផ្អែកលើផ្នែកនីមួយៗនៃតារាងវិភាគស្ថានភាពរាជធានី ខេត្តជាអាទិភាព ដែលបានរៀបចំឡើងតាមរយៈឧបករណ៍វិភាគបញ្ហា។ ***(សូមមើលសកម្មភាព ១.១.២ នៃ១.១ និងសកម្មភាព២.១ក្នុងផ្នែកទី៣ សម្រាប់ដំណើរលម្អិតនៃការរៀបចំតារាង)*** ដោយសារតារាងវិភាគស្ថានភាពបង្ហាញពីបញ្ហា និងមូលហេតុ បច្ចុប្បន្នដោយសង្ខេប ផ្នែកនេះនឹងរៀបរាប់ពីស្ថានភាពបច្ចុប្បន្ន បញ្ហា និងមូលហេតុក្នុងលក្ខណៈទូលំទូលាយ។

ការពន្យល់ពីបញ្ហា និងមូលហេតុនីមួយៗ អាចរៀបរាប់ត្រឹមមួយ ឬ ពីរកថាខណ្ឌ។

#### ១.២.១ ស្ថានភាពសេដ្ឋកិច្ច

ស្ថានភាពសេដ្ឋកិច្ចគួរបរិយាយពីបញ្ហា និងមូលហេតុក្នុងវិស័យដែលទាក់ទងនឹងចំណូលពីអាជីវកម្មបុគ្គល និងសកម្មភាពចំណូលពីសេដ្ឋកិច្ច(ឧទាហរណ៍៖ កសិកម្ម រុក្ខាប្រមាញ់ នេសាទ ឧស្សាហកម្មពាណិជ្ជកម្ម និងសេវាកម្ម)។

ឧទាហរណ៍៖ *ទិន្នផលស្រូវមានកម្រិតទាប* ជាបញ្ហាអាទិភាពមួយក្នុងចំណោម បញ្ហាអាទិភាពជាច្រើនទៀតក្នុង រាជធានី ខេត្ត។ ផ្នែកនេះ ត្រូវចាប់ផ្តើមរៀបរាប់ឱ្យបានច្បាស់លាស់ពីស្ថានភាពទិន្នផលស្រូវមានកម្រិតទាប ដោយប្រៀបធៀបទិន្នន័យរាជធានី ខេត្ត (ឧទាហរណ៍៖ទិន្នផលស្រូវជាមធ្យមក្នុងមួយហិចតា) ជាមួយនឹងទិន្នន័យជាមធ្យមនៅថ្នាក់ជាតិ ឬតារាងពិន្ទុវិស័យ។ បន្ទាប់មកត្រូវកំណត់មូលហេតុចម្បង នៃស្ថានភាពបញ្ហាធ្ងន់ធ្ងរនោះដូចជា កង្វះប្រព័ន្ធធារាសាស្ត្រ ការយល់ដឹងនៅមានកម្រិតរបស់កសិករស្តីពីជំនាញកសិកម្ម និងពូជស្រូវទិន្នផលខ្ពស់តម្លៃថ្លៃជាច្រើនប្រភេទ។

#### ១.២.២ ស្ថានភាពសង្គមកិច្ច

ស្ថានភាពសង្គមកិច្ច បរិយាយពីបញ្ហា និងមូលហេតុរបស់វិស័យដែលទាក់ទិននឹងគុណភាពនៃការរស់នៅ និងធនធានមនុស្ស(ឧទាហរណ៍៖ ការអប់រំ សុខាភិបាល សុខុមាលភាពសង្គមវប្បធម៌ជាដើម)។

ឧទាហរណ៍៖អត្រាមរណភាពរបស់កុមារអាយុក្រោមប្រាំឆ្នាំមានកម្រិតខ្ពស់ ជាបញ្ហាធ្ងន់ធ្ងរមួយក្នុង ខេត្ត។ ក្នុងករណីបែបនេះ ខេត្តត្រូវចាប់ផ្តើមរៀបរាប់ពីស្ថានភាពនៃបញ្ហាធ្ងន់ធ្ងរពីអត្រាមណភាពកុមារអាយុក្រោមប្រាំឆ្នាំ ដោយប្រៀប ធៀបទិន្នន័យពីថ្នាក់ខេត្ត (ឧទាហរណ៍៖ អត្រាមរណភាពរបស់កុមារអាយុក្រោមប្រាំឆ្នាំក្នុង១០ម៉ឺនកំណើត និងទិន្នន័យជាមធ្យមថ្នាក់ជាតិ ឬតារាងពិន្ទុវិស័យ។ បន្ទាប់មកត្រូវពន្យល់ពីមូលហេតុចម្បងនៃស្ថានភាពបញ្ហាអត្រាមរណភាពខ្ពស់នេះ ដូចជាភាគរយចាក់ថ្នាំបង្ការមានតិច កង្វះអាហារូបត្ថម្ភ ចំណេះដឹងរបស់ ម្តាយមានកម្រិតទាប និងការលំបាកនៃការទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់។ ដើម្បីកំណត់រកដំណោះស្រាយ ការងារចាំបាច់គឺត្រូវកំណត់រកមូលហេតុរងនៃមូលហេតុផ្ទាល់របស់បញ្ហា។ ឧទាហរណ៍ ភាគរយចាក់ថ្នាំបង្ការមានតិចអាចបណ្តាលមកពីចំនួនមណ្ឌលសុខភាពមិនគ្រប់គ្រាន់សម្រាប់ផ្តល់ថ្នាំបង្ការ ការយល់ដឹងរបស់ ម្តាយពីសារប្រយោជន៍នៃការចាក់ថ្នាំបង្ការនៅមានកម្រិត និងកង្វះខាតរបស់រដ្ឋាភិបាលក្នុងការផ្តល់ការចាក់ថ្នាំបង្ការដោយឥតគិតថ្លៃ ។

**១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

ស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថានគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុបរិយាយពីបញ្ហា និងមូលហេតុ នៃវិស័យដែលទាក់ទិននឹងការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងបញ្ហាបម្រែបម្រួលអាកាសធាតុ

ឧទាហរណ៍៖ *ការកាប់បំផ្លាញព្រៃឈើ*ជាបញ្ហាធ្ងន់ធ្ងរមួយ ទៅលើការគ្រប់គ្រងធនធានធម្មជាតិពីព្រោះតែវាអាចបណ្តាលឱ្យមានការបាក់ដី ដោយសារតែមានភ្លៀងធ្លាក់ខ្លាំង។ មូលហេតុនៃបញ្ហា *ការកាប់បំផ្លាញព្រៃឈើ* អាចមានច្រើន ដូចជាការកាប់ឈើយកធ្វើអុសដុត កង្វះការលើកទឹកចិត្តក្នុងការដាំដើមឈើ និងប្រជាជនយល់ដឹងតិចតួចទាក់ទិននឹងផលប៉ះពាល់នៃការកាប់ព្រៃឈើ។ ក្នុងករណីនេះ ប្រសិនបើខេត្តមានបំណងដោះស្រាយបញ្ហានៃការបំផ្លាញព្រៃឈើ ខេត្តចាំបាច់ត្រូវធ្វើការវិភាគបន្ថែមពីមូលហេតុរងនៃបញ្ហា។ ការប្រើប្រាស់ព្រៃឈើសម្រាប់ធ្វើអុសដុត អាចបណ្តាលមកពីការចំណាយខ្ពស់លើមធ្យោបាយផ្សេងទៀត (ដូចជា អគ្គីសនី ) និងការយល់ដឹងតិចតួចពីការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព និងកង្វះច្បាប់ទាក់ទិននឹងការប្រើប្រាស់ព្រៃឈើមិនត្រឹមត្រូវ។

ឧទាហរណ៍មួយទៀត៖ ទឹកជំនន់ញឹកញាប់ក្នុងរដូវវស្សាអាចកំណត់ថាជាបញ្ហាអាទិភាពមួយក្នុងខេត្ត។ បើទោះជាមើលឃើញប្រាកដថាភ្លៀងខ្លាំងគឺបណ្តាលឱ្យមានទឹកជំនន់ ហើយត្រូវបានរាប់ចូលថាជាមូលហេតុចម្បងក៏ដោយ មនុស្សពុំអាចគ្រប់គ្រងបរិមាណទឹកភ្លៀង និងមូលហេតុផ្សេងៗទៀត គួរតែត្រូវបានកំណត់ផងដែរ។ មូលហេតុផ្សេងទៀតអាចជា ប្រាំងទន្លេដែលមិនទាន់ខ្ពស់គ្រប់គ្រាន់ ទទឹ ងទន្លេតូច ការកាប់បំផ្លាញព្រៃឈើដែលស្រូបយកទឹកភ្លៀង ឬមិនមានអាងស្តុកទឹកភ្លៀង។

**១.២.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈបរិយាយពីបញ្ហា និងមូលហេតុនៃវិស័យដែលទាក់ទិននឹងរដ្ឋបាលសាធារណៈ ឧក្រិដ្ឋកម្ម គ្រោះថ្នាក់ចរាចរណ៍ ។ ល។

កំណើនគ្រោះថ្នាក់ចរាចរណ៍អាចជាបញ្ហាគួរឱ្យកត់សម្គាល់ក្នុងរាជធានី ខេត្តជាច្រើន។ មូលហេតុដែលបណ្តាលឱ្យកើតនូវស្ថានភាពបែបនេះអាចមានច្រើនដូចជា កំណើនចំនួន យានជំនិះ

ការយល់ដឹងនៅមានកម្រិតពីការបើកបរប្រកបដោយសុវត្ថិភាពក្នុងចំណោមអ្នកបើកបរ និងចំនួនភ្លើងសញ្ញាចរាចរមិនគ្រប់គ្រាន់។

**ជំពូកទី ២÷ ក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត**

ជំពូកនេះ គួររៀបរាប់ដោយផ្អែកលើតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានីខេត្ត។( សូមមើលសកម្មភាព ២.១ និង២.៤ក្នុងផ្នែកទី៣សម្រាប់ដំណើរការលម្អិតក្នុងការបង្កើតតារាងនេះ )

**២.១ ចក្ខុវិស័យអភិវឌ្ឍន៍**

ចក្ខុវិស័យអភិវឌ្ឍន៍ រៀបរាប់ពីការប្រាថ្នាចង់បាន ឬសភាពនាថ្ងៃអនាគតរបស់រាជធានី ខេត្តតាមរយៈគោលដៅជាមូលដ្ឋាន និង/ឬទិសដៅជាយុទ្ធសាស្ត្រ។

រាជធានី ខេត្តត្រូវរៀបចំមួយ ឬពីរប្រយោគដែលរៀបរាប់ពីសភាពក្នុងថ្ងៃអនាគតដែលរាជធានី ខេត្តចង់សម្រេចបានក្នុងអាណត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។

ចក្ខុវិស័យអភិវឌ្ឍន៍ត្រូវធ្វើឡើងដោយការសង្ខេបទិសដៅនានារបស់រាជធានី ខេត្តសម្រាប់ការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំដោយយោងលើយុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានី ខេត្តក្នុងផ្នែកនីមួយៗ ហើយធ្វើការផ្តោតតែទៅលើផ្នែកណាដែលរាជធានី ខេត្តចាត់ទុកថាមានអាទិភាពខ្ពស់។ ចក្ខុវិស័យអភិវឌ្ឍន៍មិនចាំបាច់លម្អិត និងគ្រប់ជ្រុងជ្រោយនោះទេ។ បើទោះជាគ្មាននិយ័តកម្មជាក់លាក់ជាកំហិត ឬចម្លើយប្រកដក្នុងការសរសេរចក្ខុវិស័យអភិវឌ្ឍន៍ក៏ដោយ ការប្រើប្រាស់នូវពាក្យគន្លឹះដើម្បីរៀបរាប់ពីទិសដៅនៃការអភិវឌ្ឍន៍រាជធានី ខេត្តគឺជាការល្អ។

ឧទាហរណ៍៖ ប្រសិនបើខេត្តមួយចង់ឱ្យការអភិវឌ្ឍន៍អេកូទេសចរណ៍ជាឧស្សាហ៍កម្មចម្បងសម្រាប់ខេត្តនោះចក្ខុវិស័យអាចជា "ការរីកចម្រើនរបស់ឧស្សាហកម្មតាមរយៈការអភិវឌ្ឍន៍អេកូទេសចរណ៍ និងការការពារបរិស្ថាន"។

**២.២. គោលបំណងអភិវឌ្ឍន៍**

គោលបំណងអភិវឌ្ឍន៍ គឺជាការបរិយាយពីលទ្ធផលរួមដែលក្រុមប្រឹក្សារាជធានី ខេត្ត រំពឹងថានឹងសម្រេចឱ្យបានតាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍របស់រាជធានី ខេត្ត ដែលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍របស់រាជធានី ខេត្ត។

**២.៣. គោលដៅអភិវឌ្ឍន៍**

គោលដៅអភិវឌ្ឍន៍ គឺជាការបរិយាយអំពីលទ្ធផលនានាដែលក្រុមប្រឹក្សារាជធានីរំពឹងថានឹងសម្រេចបានតាមវិស័យនីមួយៗ តាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍របស់រាជធានី ខេត្ត ដែលរួមចំណែកក្នុងការសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍របស់រាជធានី ខេត្ត ។

**២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍**

ផ្នែកនេះ គួរបរិយាយពីយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ផ្នែកនីមួយៗ ផ្អែកលើ"ក្របខ័ណ្ឌអភិវឌ្ឍន៍"។ "តារាងក្របខ័ណ្ឌអភិវឌ្ឍន៍" រួមមានព័ត៌មានស្តីពីគោលបំណង គោលដៅ ដំណោះស្រាយ សូចនាករ អង្គភាពទទួលខុសត្រូវ និងប្រភពទិន្នន័យ។ ប៉ុន្តែផ្នែកនេះគ្រាន់តែបរិយាយសង្ខេបនូវគោលបំណង គោលដៅ និងដំណោះស្រាយ ប៉ុណ្ណោះ។ ការបំពេញកូឡោនផ្សេងទៀតដូចជាសូចនាករ អង្គភាពទទួលខុសត្រូវ និងប្រភពទិន្នន័យក្នុងតារាង ក្របខ័ណ្ឌអភិវឌ្ឍន៍មិនត្រូវបញ្ចូលក្នុងផ្នែកនេះទេ ។

២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

ផ្នែកនេះ បរិយាយពីយុទ្ធសាស្ត្រទាំងមូលនៃផ្នែកសេដ្ឋកិច្ច ដោយសង្ខេបពីទិសដៅនៃការអភិវឌ្ឍក្នុងវិស័យដែលទាក់ទងនឹងសេដ្ឋកិច្ច។ ផ្នែកនេះរៀបរាប់លម្អិតនៃយុទ្ធសាស្ត្រផ្នែកសេដ្ឋកិច្ច។ យុទ្ធសាស្ត្រនីមួយៗគឺជាសេចក្តីសង្ខេបនៃទិសដៅអភិវឌ្ឍន៍ដោយយោងតាមព័ត៌មានក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត ។ គោលបំណង គោលដៅ និងដំណោះស្រាយនីមួយៗ គួរពន្យល់ដោយសង្ខេបជាពីរឬបី (០២ឬ០៣) ប្រយោគ។

**តារាងគំរូ៖ គោលបំណង គោលដៅ និងដំណោះស្រាយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច**

| គោលបំណង និងគោលដៅ | ដំណោះស្រាយ |
|---|---|
| ១. គោលបំណង៖<br>ប្រាក់ចំណូលពីសហគ្រាសខ្នាតតូច និងមធ្យមមានការកើនឡើងនៅតំបន់ជនបទ។ | |
| ១.១ គោលដៅ៖<br>សហគ្រាសខ្នាតតូច និងមធ្យមឆ្លើយតបនឹងតម្រូវការទីផ្សារ។ | ១.១.១ គុណភាពនៃផលិតផលសហគ្រាសខ្នាតតូច និងមធ្យមមានភាពប្រសើរឡើង។<br>១.១.២ សហគ្រាសខ្នាតតូច និងមធ្យមមានលទ្ធភាពទទួលបានព័ត៌មានពីទីផ្សារ។<br>១.១.៣ អាជ្ញាធរពាក់ព័ន្ធអាចរៀបចំកម្មវិធីគាំទ្រសហគ្រាសខ្នាតតូច និង មធ្យម។ |
| ១.២ គោលដៅ៖<br>លទ្ធភាពចូលទៅកាន់ទីផ្សារមានភាពប្រសើរឡើង។ | ១.២.១ មធ្យោបាយដឹកជញ្ជូនទៅកាន់ទីផ្សារដែលទុកចិត្តបាន មានសម្រាប់ប្រើប្រាស់។<br>១.២.២ ប្រជាពលរដ្ឋអាចទទួលព័ត៌មានស្តីពីតម្រូវការទីផ្សារទាន់ពេល វេលា។ |
| ២. គោលបំណង៖<br>ផលិតផលកសិកម្មក្នុងជំនួញខ្នាតតូចមានភាពប្រកួតប្រជែងក្នុងទីផ្សារ។ | |
| ២.១ គោលដៅ:<br>លទ្ធភាពចូលដល់ទីផ្សារមានភាពប្រសើរឡើង។ | ២.១.១ ផលិតផលកសិកម្មមូលដ្ឋានត្រូវបានផ្សព្វផ្សាយយ៉ាងល្អនៅក្នុងទីផ្សារ។<br>២.១.២ ក្រុមការងារកសិកម្មធ្វើការសម្របសម្រួលព័ត៌មានទីផ្សារ។<br>២.១.៣ កសិករមានជម្រើសផ្សេងទៀតក្នុងការលក់ផលិតផលរបស់ពួកគេ ដោយមិនចាំបាច់តែពឹងលើឈ្មួញកណ្តាលនោះទេ។ |
| ២.២ គោលដៅ៖<br>ឧបសគ្គជារូបវន្តក្នុងជំនួញផលិតផលកសិកម្មត្រូវបានកាត់ប | ២.២.១<br>ការចំណាយរដ្ឋបាលក្រៅផ្លូវការត្រូវបានកាត់បន្ថយ។ |

| | |
|---|---|
| ន្តយ។ | ២.២.២<br>ទីផ្សារមូលដ្ឋានទទួលយកផលិតផលកសិកម្មពីតំបន់ខាងក្រៅ។ |

ប្រសិនបើគោលបំណងគឺ "ប្រាក់ចំណូលពីសហគ្រាសខ្នាតតូច និងមធ្យមមានការកើនឡើងនៅតំបន់ជនបទ" និង"ផលិតផលកសិកម្មក្នុងជំនួញខ្នាតតូចមានភាពប្រកួតប្រជែងក្នុងទីផ្សារ"
ដូច្នេះការរៀបរាប់ត្រូវធ្វើដូចខាងក្រោមនេះ៖

**គោលបំណងទី១៖** ប្រាក់ចំណូលពីសហគ្រាសខ្នាតតូច និងមធ្យមមានការកើនឡើង។

ដើម្បីសម្រេចបានគោលបំណងនេះ គោលដៅពីរត្រូវបានកំណត់៖ សហគ្រាសខ្នាតតូច និងមធ្យមឆ្លើយតបនឹងតម្រូវការទីផ្សារ និងលទ្ធភាពចូលទៅកាន់ទីផ្សារមានភាពប្រសើរឡើង។
ដើម្បីសម្រេចបានគោលដៅទី១ សហគ្រាសខ្នាតតូច និងមធ្យមឆ្លើយតបនឹងតម្រូវការទីផ្សារ ដំណោះស្រាយជាអាទិភាពបី (០៣) ត្រូវបានកំណត់៖ គុណភាពនៃផលិតផលសហគ្រាសខ្នាតតូច និងមធ្យមមានភាពប្រសើរឡើង សហគ្រាសខ្នាតតូច និងមធ្យមមានលទ្ធភាពទទួលបានព័ត៌មានពីទីផ្សារ ហើយអាជ្ញាធរពាក់ព័ន្ធអាចរៀបចំកម្មវិធីគាំទ្រសហគ្រាសខ្នាតតូច និងមធ្យម។ ដូចនេះដើម្បីសម្រេចបានគោលដៅទី១ សកម្មភាពជាក់ ស្តែង ឬគម្រោងត្រូវមានដូចជា៖ ១) ការធ្វើឱ្យប្រសើរឡើងនូវគុណភាពផលិតផលសហគ្រាសខ្នាតតូច និងមធ្យម ២) ការលើកកម្ពស់ព័ត៌មានទីផ្សារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងទី៣) ការគាំទ្រសហគ្រាសខ្នាតតូច និងមធ្យមពីសំណាក់អាជ្ញាធរពាក់ព័ន្ធ។
ដើម្បីសម្រេចគោលដៅទី២ លទ្ធភាពចូលទៅកាន់ទីផ្សារមានភាពប្រសើរឡើង ដំណោះស្រាយជាអាទិភាពពីរ (០២) ត្រូវបានកំណត់៖ មធ្យោបាយដឹកជញ្ជូនទៅកាន់ទីផ្សារដែលទុកចិត្តបានមានសម្រាប់ប្រើប្រាស់ និងប្រជាពលរដ្ឋអាចទទួលព័ត៌មានស្តីពីតម្រូវការទីផ្សារទាន់ពេលវេលា។ ដូចនេះដើម្បីសម្រេចបានគោលដៅទី២ សកម្មភាពជាក់ស្តែង ឬ គម្រោងត្រូវមានដូចជា៖ ១) ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់មធ្យោបាយធ្វើដំណើរសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និង២) ការធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មានអំពី ទីផ្សារទាន់ពេលវេលា។

**គោលបំណងទី២៖** ផលិតផលកសិកម្មក្នុងជំនួញខ្នាតតូចមានភាពប្រកួតប្រជែងក្នុងទីផ្សារ។

ដើម្បីសម្រេចបានគោលបំណងនេះ គោលដៅពីរត្រូវបានកំណត់៖ លទ្ធភាពចូលដល់ទីផ្សារមានភាពប្រសើរឡើង និង ឧបសគ្គជារូបវ័ន្តក្នុងជំនួញផលិតផលកសិកម្មត្រូវបានកាត់បន្ថយ។ ដើម្បីសម្រេចបានគោលដៅទី១ លទ្ធភាពចូលដល់ទីផ្សារមានភាពប្រសើរឡើង ដំណោះស្រាយជាអាទិភាពបី (០៣) ត្រូវបានកំណត់៖ ផលិតផលកសិកម្មមូលដ្ឋានត្រូវបានផ្សព្វផ្សាយយ៉ាងល្អក្នុងទីផ្សារ, ក្រុមការងារកសិកម្មធ្វើការសម្របសម្រួលព័ត៌មានទីផ្សារ
និងកសិករមានជម្រើសផ្សេងទៀតក្នុងការលក់ផលិតផលរបស់ពួកគេដោយមិនចាំបាច់តែពឹងលើឈ្មួញកណ្តាលនោះទេ។ ដូចនេះដើម្បីសម្រេចបានគោលដៅទី១ សកម្មភាពជាក់ស្តែង ឬគម្រោងត្រូវមានដូចជា៖ ១) ការលើកកម្ពស់ផលិតផលកសិកម្មក្នុងទីផ្សារ,

២)ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ក្រុមការងារកសិកម្មពាក់ព័ន្ធនឹងព័ត៌មានទីផ្សារ និងទី៣) ការបង្កើតកន្លែងតូចៗសម្រាប់លក់ផលិតផលកសិកម្មរបស់កសិករ។

ដើម្បីសម្រេចគោលដៅទី២ ឧបសគ្គជារូបវន្តក្នុងជំនួញផលិតផលកសិកម្មត្រូវបានកាត់បន្ថយ ដំណោះស្រាយជា អាទិភាពពីរ (០២) ត្រូវបានកំណត់៖ ការចំណាយរដ្ឋបាលក្រៅផ្លូវការត្រូវបានកាត់បន្ថយ និងទីផ្សារ មូលដ្ឋានទទួលយកផលិតផលកសិកម្មពីតំបន់ខាងក្រៅ ។ ដូច នេះដើម្បីសម្រេចបានគោលដៅទី២ សកម្មភាពជាក់ស្តែង ឬគម្រោងត្រូវមាន ដូចជា៖ ១) ការលុបបំបាត់ការចំណាយរដ្ឋបាលក្រៅផ្លូវការ និង២)ការការពារការរើសអើងផលិតផលកសិកម្មក្នុងទីផ្សារ។

### ២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

ផ្នែកនេះ បរិយាយពីយុទ្ធសាស្ត្រទាំងមូលនៃផ្នែកសង្គមកិច្ច ដោយសង្ខេបពីទិសដៅនៃការអភិវឌ្ឍក្នុង វិស័យដែលទាក់ទងនឹងសង្គមកិច្ច។ ផ្នែកនេះរៀបរាប់លម្អិតនៃយុទ្ធសាស្ត្រផ្នែកសង្គមកិច្ច។ យុទ្ធសាស្ត្រនីមួយៗ គឺជាសេចក្តីសង្ខេបនៃទិសដៅអភិវឌ្ឍន៍ដោយយោងតាមព័ត៌មានក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត ។ គោលបំណង គោលដៅ និងដំណោះស្រាយនីមួយៗ គួរពន្យល់ដោយសង្ខេបជាពីរឬបី (០២ឬ០៣) ប្រយោគ។

**ឧទាហរណ៍៖** ផ្អែកតាមបញ្ហាអាទិភាពនៃ *អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំខ្ពស់* អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំទាប គឺជាគោលបំណង។ ករណីនេះ គោលដៅអាចរួមមាន៖ ការយល់ដឹងកាន់តែប្រសើរអំពីអាហារូបត្ថម្ភសម្រាប់កុមារអាយុក្រោម៥ឆ្នាំ ការទទួលព័ត៌មានកាន់តែប្រសើរពីការចាក់ថ្នាំបង្ការ និងការលើកកម្ពស់ការដឹកជញ្ជូនថ្នាំពេទ្យទៅកាន់មណ្ឌលសុខភាព។ បន្ទាប់មក ដំណោះស្រាយត្រូវកំណត់តាមគោលដៅនីមួយៗរួមមាន៖ ការផ្សព្វផ្សាយពីការចាក់ថ្នាំបង្ការតាមរយៈកម្មវិធីវិទ្យុ ការផ្តល់ថ្នាំបង្ការដោយឥតគិតថ្លៃ និងការធ្វើដំណើរទៅកាន់សហគមន៍ជាប្រចាំរបស់បុគ្គលិកមណ្ឌលសុខភាពដើម្បីផ្តល់ថ្នាំបង្ការ។

### ២.៤.៣ យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ផ្នែកនេះ បរិយាយពីយុទ្ធសាស្ត្រទាំងមូលនៃការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ ដោយសង្ខេបពីទិសដៅនៃការអភិវឌ្ឍក្នុងវិស័យដែលទាក់ទងនឹងការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធាន ធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដោយយោងតាមព័ត៌មានក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍។ គោលបំណង គោលដៅ និង ដំណោះស្រាយនីមួយៗ គួរពន្យល់ដោយសង្ខេបជាពីរឬបី (០២ឬ០៣) ប្រយោគ។

**ឧទាហរណ៍៖** ការធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រងកាកសំណល់រឹងក្នុងទីរួមខេត្ត អាចកំណត់បានជាគោលបំណង។ ករណីនេះ គោលដៅជាច្រើនអាចរួមមាន៖ ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងការប្រមូលសំណល់រឹង ការសាងសង់ទីលានចាក់សំរាម និងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋពីការគ្រប់គ្រងសំណល់រឹងឱ្យ បានត្រឹមត្រូវ

### ២.៤.៤ យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ផ្នែកនេះ បរិយាយពីយុទ្ធសាស្ត្រទាំងមូលនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដោយសង្ខេបពីទិសដៅនៃការអភិវឌ្ឍក្នុងវិស័យដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ សាធារណៈ ដោយយោងតាមព័ត៌មានក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍គោលបំណង គោលដៅ និងដំណោះស្រាយ នីមួយៗគួរពន្យល់ដោយសង្ខេបជាពីរឬបី(០២ឬ០៣) ប្រយោគ។

**ឧទាហរណ៍៖** <u>ការកាត់បន្ថយបទឧក្រិដ្ឋក្នុងទីប្រជុំក្រុង</u> អាចកំណត់ជាគោលបំណងអាទិភាព។ ករណីនេះ គោលដៅអាចរួមមាន៖ ការដើរល្បាតរបស់ប៉ូលីសពេលយប់ជាប្រចាំ ការដាក់ភ្លើងបំភ្លឺផ្លូវ និងការផ្សព្វផ្សាយពីវិធានការបង្ការតាមកម្មវិធីវិទ្យុ។

### ២.៥ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវរៀបចំឡើង ដើម្បីផ្តើមគណនាប៉ាន់ស្មានអំពីតម្រូវការចំណាយ ដែលជាមូលដ្ឋាន ដើម្បីបំពេញផែនការអភិវឌ្ឍន៍ឱ្យទៅជាសកម្មភាពគម្រោងរបស់រដ្ឋបាលនានា។ សេចក្តីណែនាំលម្អិតសម្រាប់រៀបចំក្របខ័ណ្ឌចំណាយនឹងផ្តើរណែនាំជាក្រោយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍

ជំពូកនេះ គួរបរិយាយពីផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ រួមមានព័ត៌មានស្តីពីវិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ តារាងពេលវេលា និងអង្គភាពទទួលបន្ទុកការសម្របសម្រួលទាំងមូល។ តារាងផែនការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ត្រូវបានភ្ជាប់នៅទីនេះ។ (សូមមេត្តាមើលឧបសម្ព័ន ៥ .៥ តារាងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ)។

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ គឺជាបណ្តាឯកសារយោងសម្រាប់បង្កើនទម្ងន់នៃចំណុចពាក់ព័ន្ធណាមួយ ហេតុនេះ ការបញ្ចូលឯកសារឧបសម្ព័ន្ធក្នុងសៀវភៅផែនការអភិវឌ្ឍន៍ជាការសម្រេចចិត្តរបស់រាជធានីខេត្ត។

ឯកសារដែលអាចបញ្ចូលជាឧបសម្ព័ន្ធរួមមាន ៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត
- តារាងអាទិភាពនៃការវិភាគស្ថានភាពរាជធានី ខេត្ត
- តារាងក្របខ័ណ្ឌការអភិវឌ្ឍន៍រាជធានី ខេត្ត
- លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ផែនទីសំខាន់ៗ ដូចជាផែនទីនៃការប្រើប្រាស់ដីធ្លីនិង ផែនទីតំបន់ទេសចរណ៍។ល។